# មេរៀនទី ៩៤៖ នាងរស់តក្តីភាពចំពោះម្តាយក្មេក

នាងរស់ ១៖១-២២

**មេរៀនសម្រាប់គ្រូ** (*យូធូបលីង*)៖ https://youtu.be/B7ZxHnfHpEI

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/sZ3NiC14mzo

**គោលបំណង៖** ព្រះប្រទានការកំសាន្តចិត្តដល់យើង។

**ខគម្ពីរចងចាំ៖ ហេព្រើរ ១៣៖៥** *"អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ។"*

**ចំរៀង** (*យូធូបលីង*)៖

១. ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/aasilZXGorc
២. ខ្ញុំបានសំរេចចិត្ត https://youtu.be/MR1Yv--Q4oo
៣. ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ https://youtu.be/VvrF94VKKHA

## ១. អធិស្ឋាន

## ២. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

## ៣. ល្បែងកំសាន្ត «ធ្វើម្ហូប»



១. ឲ្យកុមារទាំងអស់អង្គុយជារង្វង់នៅលើកៅអី

២.គ្រូជ្រើសរើសកុមារម្នាក់ធ្វើជាអ្នកដើរផ្សារទិញម្ហូប រួចដកកៅអីគាត់ចេញ ហើយកុមារទាំងអស់ដើរតួជាទំនិញ

៣. អ្នកទិញត្រូវកត់គ្រឿងផ្សំទាំងអស់ ដែលគាត់ត្រូវការក្នុងការធ្វើម្ហូបនោះ។ ហើយគេអាចជ្រើសកុមារណាម្នាក់ក៏បាន ក្នុងការ ធ្វើជាគ្រឿងផ្សំណាមួយក៏បាន។ នៅពេលដែលអ្នកទិញរើសកុមារណាម្នាក់ហើយ កុមារនោះត្រូវដើរតាមអ្នកទិញនោះ។ ហើយកុមារជាជាគ្រឿងទេសដែលត្រូវបានគេជ្រើសរើសនោះត្រូវធ្វើកាយវិកាត្រាប់តាមអ្នកទិញផងដែរ។ ឧទាហរណ៍៖ នៅពេលដែលអ្នកទិញធ្វើកាយវិការនឿយហត់ ដួល ឬក៏ អង្គុយចុះនោះ (ឬក៏កាយវិការផ្សេងទៀត) កុមារផ្សេងទៀតដែលបានជ្រើសរើសរួចនោះ ត្រូវធ្វើកាយវិការតាមអ្នកទិញនោះ។

៤. នៅពេលដែលគ្រូនិយាយថា "អ្នកទិញអស់លុយហើយ" កុមារទាំងអស់ត្រូវស្វែងរកកៅអី ដើម្បីអង្គុយចុះ។ ប្រសិនបើកុមារណាម្នាក់មិនអាចរកកៅអីអង្គុយបាន អ្នកនោះត្រូវធ្វើជាអ្នកដើរទិញវិញម្តង។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា គ្រឿងផ្សំទាំងអស់ត្រូវដើរតាមអ្នកទិញ។ ថ្ងៃនេះយើងនឹងរៀនពី នាងរស់ដែលមានភក្តីភាពចំពោះម្តាយក្មេក និងចំពោះព្រះ។

## ៤. ការណែនាំមេរៀន

យើងដឹងថាព្រះគ្រប់ល័ក្ខ គ្មានអ្នកណាគ្រប់ល័ក្ខដូចជាទ្រង់ឡើយ។ ព្រះមិនដែលធ្វើអ្វីខុសទេ ព្រះឆ្លើយតបការអធិស្ឋានរបស់យើង។ យើងដឹងថាព្រះមានសេចក្តីមេត្តាករុណា។ ព្រះយកចិត្តទុកដាក់យើង ទោះបីជាយើងសាកសម ឬមិនសាកសមនឹងទទួលក្តីមេត្តារបស់ទ្រង់ក៏ដោយ។ ព្រះនឹងតែងតែគង់ជាមួយ

យើង ដើម្បីកំសាន្តចិត្តយើង។ ហើយព្រះអង្គនឹងមិនផ្លាស់ប្តូរទេ។ នៅពេលដែលយើងទុកចិត្តទ្រង់ ទ្រង់នឹង ប្រទានសន្តិភាពឲ្យយើង។ នេះជាផ្នែកមួយដែលទ្រង់កំសាន្តចិត្តយើង។ នេះជាអារម្មណ៍នៅខាងក្នុងដែលថាគ្រប់យ៉ាងនឹងមិនអីទេ ពីព្រោះព្រះនឹងមើលថែគ្រប់ការទាំងអស់។ ថ្ងៃនេះយើងនឹងរៀនពី ព្រះអង្គបានកំសាន្តចិត្តស្ត្រី ២នាក់ដែលកំពុងតែមានទុក្ខសោក។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

មានស្ត្រីម្នាក់ឈ្មោះន៉ាអូមីជាអ្នកនៅក្រុងបេថ្លេហិម។ នៅស្រុកកំណើតរបស់នាងធ្លាប់កើតមានអំណត់អត់-គ្មាននរណាមានបាយហូបទេ។ ដូច្នេះហើយនាងន៉ាអូមី និងប្តីរបស់នាង ព្រមទាំងកូនប្រុសទាំង២បាននាំគ្នាទៅនៅឯស្រុកម៉ូអាប់វិញ។ មានអាហារច្រើននៅក្នុងស្រុកម៉ូអាប់។ ខណៈពេលដែលន៉ាអូមីរស់នៅក្នុងស្រុកម៉ូអាប់ កូនប្រុសទាំង២របស់នាងបានរៀបការ ដូច្នេះសមាជិកគ្រួសាររបស់នាងកាន់តែរីកធំជាងមុន។ បន្ទាប់មកមានរឿងសោកសៅមួយបានកើតឡើងក្នុងគ្រួសារនាង។ ប្តី និងកូនប្រុសទាំង២របស់ន៉ាអូមីបានស្លាប់ទាំងអស់។

បន្ទាប់ពីប្តី និងកូនប្រុសទាំង២របស់នាងបានស្លាប់បាត់ទៅ ន៉ាអូមីនៅឯកាតែឯង ពីព្រោះសាច់ញាតិរបស់នាងទាំងអស់គឺរស់នៅឯក្រុងបេថ្លេហិម។ ន៉ាអូមីក៏បានសំរេចចិត្តធ្វើដំណើរត្រឡប់ទៅបេថ្លេហិមវិញ។ ពីព្រោះកូនប្រសារន៉ាអូមីទាំង២មិនមែនជនជាតិយូដាទេ(ពួកគាត់ទាំង២ជាជនជាតិម៉ូអាប់) ន៉ាអូមីក៏បានប្រាប់ពួកគេទាំង២ថា ពួកគេមានសេរីភាព ហើយពួកគេអាចត្រឡប់ទៅផ្ទះរបស់ពួកគេវិញបាន។ កូនប្រសារ ឈ្មោះអ័រប៉ាបានសំរេចចិត្តធ្វើដំណើរត្រឡប់ទៅរកគ្រួសាររបស់នាង និងរស់នៅក្នុងស្រុក ម៉ូអាប់វិញ។

កូនប្រសារម្នាក់ទៀតឈ្មោះ នាងរស់ បានឆ្លើយតបទៅនាងន៉ាអូមី វិញថា នាងនឹងមិនចាកចោលន៉ាអូមីទេ ពីព្រោះនាងមិនចង់ឲ្យន៉ាអូមីនៅឯកាតែឯង។ **នាងរស់ ១៖១៦** *"តែនាងឆ្លើយថា សូមកុំទទូចឲ្យខ្ញុំទៅចោលនកម្តាយ និងវិលទៅវិញ លែងតាមអ្នកម្តាយនោះឡើយ ដ្បិតកន្លែងណាដែលអ្នកម្តាយអញ្ជើញទៅ នោះខ្ញុំនឹងទៅតាម ហើយកន្លែងដែលអ្នកម្តាយស្នាក់នៅ នោះខ្ញុំក៏នឹងនៅដែរ សាសន៍របស់អ្នកម្តាយនឹងបានជាសាសន៍របស់ខ្ញុំ ហើយព្រះរបស់អ្នកម្តាយនឹងបានជាព្រះរបស់ខ្ញុំដែរ"* នាងរស់ដឹងថា ជីវិតជាស្ត្រីមេម៉ាយគឺពិបាកណាស់ ពីព្រោះជាពិសេសនោះនាងរស់ត្រូវមើលថែន៉ាអូមី ដែលជាស្ត្រីមេម៉ាយវ័យចំណាស់។ ប៉ុន្តែនាងរស់មានចិត្តស្មោះត្រង់នៅចំពោះព្រះ ហើយនាងបានសំរេចចិត្តមានភក្តីភាពចំពោះម្តាយក្មេកនាង។ ដូច្នេះនាងរស់ និងន៉ាអូមីបានធ្វើដំណើរត្រឡប់ទៅបេថ្លេហិមវិញ។

ពេលវេលាលំបាកកើតឡើងចំពោះមនុស្សគ្រប់គ្នា ប៉ុន្តែព្រះតែងតែកំសាន្តចិត្តយើង ពីព្រោះព្រះអង្គស្រលាញ់យើង ហើយទ្រង់ចង់មើលថែយើង។ ព្រះគម្ពីរបានប្រាប់យើងថាការកំសាន្តចិត្តរបស់ព្រះតែងតែមកដល់តាមរយៈមនុស្សដែលមានជំនឿលើព្រះអង្គ។ នាងរស់ជាធនធានមួយដ៏អស្ចារ្យក្នុងការកំសាន្តចិត្តន៉ាអូមីជាស្ត្រីមេម៉ាយដែលមិនអាចរស់នៅតែឯងបាន។ ព្រះចង់កំសាន្តចិត្តយើងគ្រប់គ្នានៅពេលដែលយើងជួបទុក្ខលំបាក ហើយព្រះក៏ចង់ប្រើយើងនាំនូវការកំសាន្តចិត្តដល់មនុស្សនៅជុំវិញខ្លួនយើងដែរ។

## ៦. សំនួរពិភាក្សា

១. តើមានរឿងសោកសៅអ្វីខ្លះដែលបានកើតឡើងចំពោះន៉ាអូមី? *(ភាពអំណត់អត់ឃ្លាននៅក្នុង ប្រទេសរបស់នាង ប្តី និងកូនប្រុសបានស្លាប់ នាងក៏ឯកោ)*

២. តើមានរឿងល្អអ្វីខ្លះដែលបានកើតឡើងចំពោះន៉ាអូមី? *(មានអាហារច្រើននៅស្រុកម៉ូអាប់ កូនប្រុសរបស់នាងបានរៀបការ នាងរស់បានសម្រេចចិត្តផ្លាស់ទៅបេថ្លេហិមជាមួយនាង ហើយរស់នៅជាមួយនាង)*

៣. តើមានរឿងសោកសៅអ្វីខ្លះដែលបានកើតឡើងចំពោះអ្នក ឬក្រុមគ្រួសាររបស់អ្នក? *(ឱ្យកុមារឆ្លើយ)*
៤. តើអ្នកឬក្រុមគ្រួសាររបស់អ្នកបានកំសាន្តចិត្តយ៉ាងណា ពេលមានរឿងសោកសៅកើតឡើងចំពោះអ្នក អ្នកនិងក្រុមគ្រួសារអ្នក? *(ឱ្យកុមារឆ្លើយ)*
៥. តើព្រះអាចប្រើអ្នកដើម្បីកំសាន្តចិត្តអ្នកឯទៀតយ៉ាងដូចម្តេច? *(ធ្វើជាមិត្តល្អ ជួយអ្នកដទៃ កំសាន្តចិត្តអ្នកដែលមានទុក្ខ។ល។)*

## ៧. ល្បែងកំសាន្ត

សំភារៈដែលត្រូវការៈ ក្រដាស២ព៌ណខុសគ្នា



១. បែងចែកកុមារជា២ក្រុម
២.ឲ្យក្រដាសទៅកុមារម្នាក់១សន្លឹក ហើយឲ្យពួក គេបត់ក្រដាសនោះទៅជារូបយន្តហោះ
៣. ពេលដែលកុមារគ្រប់គ្នាបត់ក្រដាសយន្តហោះហើយ ឲ្យកុមារទាំងអស់ឈរជាជួរទៅតាមក្រុម របស់ពួកគេ។
៤. កុមារត្រូវប្តូរវេនគ្នា មកឈរនៅខាងមុខគំនូសចាប់ផ្តើម ហើយគប់យន្តហោះក្រដាសទៅមុខ។ កុមារដែលគប់យន្តហោះក្រដាស់បានឆ្ងាយជាងគេនឹងបានពិន្ទុសំរាប់ក្រុមគេ។
៥. ក្រុមណាដែលបានពិន្ទុច្រើនជាងគេគឺជាអ្នកឈ្នះ
៦. បន្ទាប់ពីលែងហ្គេមចប់ ពន្យល់កុមារថា ទោះបីជាយើងមើលមិនឃើញខ្យល់ ពេលដែលយើងគប់យន្តហោះ ក្រដាសចេញទៅក៏ដោយ ក៏នៅតែមានខ្យល់នៅទីនោះ។ ក៏ដូចជាយើងដែលមិនអាចមើលឃើញព្រះក៏ដោយ ក៏ព្រះអង្គនៅតែនៅក្បែរយើងមើលថែ និងកំសាន្តចិត្តយើងនៅពេលដែលយើងត្រូវទ្រង់។

## ៨. ខគម្ពីរចងចាំ

**ហេព្រើរ ១៣៖៥** *“អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ។”*

**៩. ហាត្ថកម្ម៖** ឲ្យកុមារផាត់ព៌ណ **«នាងរស់ស្មោះត្រង់»**

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវជាមិត្តសម្លាញ់ដ៏ស្មោះត្រង់ចំពោះយើង ហើយព្រះអង្គសប្បាយចិត្តនៅពេលដែលយើងព្យាយាមធ្វើឲ្យដូចទ្រង់ដោយជាមិត្តសម្លាញ់ដ៏ស្មោះត្រង់ជាមួយនឹងមិត្តភក្តិយើង ហើយស្រលាញ់ពួកគេមិនថាមានបញ្ហាអ្វីក៏ដោយ។ នៅក្នុងសាច់រឿងព្រះគម្ពីថ្ងៃនេះ នាងរស់មានជំរើសៈធ្វើអ្វីៗដែលអាចនាំមកនូវផលប្រយោជន៍សំរាប់ខ្លួននាង ឬស្មោះត្រង់ ភក្តីភាព ហើយទៅជាមួយម្តាយក្មេករ័យចំណាស់របស់នាង។ តើពេលណាដែលអ្នកត្រូវបានគេល្បួងឲ្យបោះបង់មិត្តសម្លាញ់ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន? ទូលសូមព្រះប្រទានពរឲ្យអ្នកនូវជំនឿ និងកម្លាំងក្នុងថ្ងៃនេះ ដូច្នេះហើយអ្នកអាចនឹងមានភក្តីភាពចំពោះមិត្តភក្តិអ្នកបាន។

# នាងរស់ស្មោះត្រង់

*“អ្នកអញ្ជើញទៅទីណា ខ្ញុំនឹងទៅទីនោះដែរ,*
*ហើយអ្នកស្នាក់នៅទីណា ខ្ញុំនឹងនៅទីនោះដែរ ”*



សូមសរសេរខគម្ពីរចងចាំ:________________________________________

________________________________________________________